**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

**សូមគោរពជូន**

**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា**

**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុ**

***សម្តេចមហារដ្ឋសភាធិការធិបតី ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !***

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ នាឱកាសដ៏នក្ខត្តឫក្ស នៃពិធីចម្រើនជន្មាយុ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **សម្តេចមហារដ្ឋសភាធិការធិបតី** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នរដ្ឋសភាឱ្យមានការរីកចម្រើនថែមទៀត។

នាឱកាសដ៏សោមនស្សរីករាយនេះផងដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រចំពោះ**សម្តេច** ប្រធានរដ្ឋសភា ដែលជានិច្ចកាលតែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយនិងប្រាជ្ញាស្មារតីជាមួយនឹងបទពិសោធន៍ដ៏ឈ្លាសវៃ និងប៉ិនប្រសប់ ក្នុងការជួយជ្រោមជ្រែងស្ថាប័នរដ្ឋសភាឱ្យសម្រេចបាននូវសមិទ្ធផលជាច្រើនគួរឱ្យស្ងប់ស្ងែង និងបានជំរុញឱ្យស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នកំពូលរបស់ជាតិ មានការរីកចម្រើនឥតឈប់ឈរ រួមចំណែកដល់ការលើកកម្ពស់នីតិរដ្ឋ ស្របតាមបំណងប្រាថ្នាដែលប្រជាជនចង់បាន។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះ **សម្តេចមហារដ្ឋសភាធិការធិបតី** និងក្រុមគ្រួសារ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃពុធ ១០ កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ សីហា**

វិថីហ្សកនីមិត្រ្ត សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៨៣ ២៧៩: generalsec@mod.gov.kh